Version 2018



EAST-WEST SEED

# សារធាតុចិញ្ចឹមសំខាន់ៗ

## ការណែនាំអំពីបច្ចេកទេស



CAMBODIA

## តើអ្វីជាសារធាតុចិញ្ចឹមសំខាន់ៗ?

*សារធាតុចិញ្ចឹមដែលរុក្ខជាតិត្រូវការក្នុងបរិមាណច្រើនសំរាប់ការលូតលាស់។

រុក្ខជាតិត្រូវការសារធាតុ
ចិញ្ចឹមជាច្រើនទៀតក្រៅពីអាសូត (N) ។



O C H

បានពីខ្យល់
(សមាសភាគសម្ព័ន្ធ)

### សារធាតុចិញ្ចឹមសំខាន់ៗ ឬម៉ាក្រូធាតុ

S Mg Ca

N K P

### សារធាតុចិញ្ចឹមដែលរុក្ខជាតិត្រូវការតិចតួច ឬមីក្រូធាតុ

B Moi Cl Co

Mn Zn Cu Fe Ni

## សារធាតុចិញ្ចឹមសំខាន់ៗទាំង ១៨មុខដែលរុក្ខជាតិត្រូវការ

## • មុខងាររបស់សារធាតុចិញ្ចឹមសំខាន់ៗ




**អាសូត ( N )**

* ចូលរួមក្នុងរស្មីសំយោគ
* ជំរុញការលូតលាស់របស់រុក្ខជាតិ

**ផូស្វ័រ ( P )**

* ជំរុញការលូតលាស់របស់ឫស
* ជំរុញភាពទុំ

**ប៉ូតាស្យូម ( K )**

* ធ្វើអោយផ្លែមានគុណភាពប្រសើរឡើង
* បង្កើនការធន់ទ្រាំនឹងជម្ងឺ

**ម៉ាញ៉េស្យូម ( Mg )**

* គ្រប់គ្រងការស្រូបយកសារធាតុ ចិញ្ចឹមផ្សេងទៀត
* ជាសារធាតុចិញ្ចឹមសំខាន់ក្នុងការផលិតក្លរ៉ូភីល (រុក្ខជាតិបៃតង)

**ស្ពាន់ធ័រ ( S )**

* ជំរុញការបង្កើតកំពកឫសលើដំណាំអំបូរ សណ្តែក
* ជួយបង្កើនការលូតលាស់របស់ឫស និងបង្កើតគ្រាប់

**កាល់ស្យូម ( Ca )**

* បង្កើនការចេញផ្លែ
* បង្កើនការធន់ទ្រាំនឹងជម្ងឺ

**ប្រអប់គន្លឹះ៖**

ការគ្រប់គ្រងទឹកបានល្អធានានូវការស្រូបយកសារធាតុចិញ្ចឹមរុក្ខជាតិបាន ល្អ។

# • រោគសញ្ញាកង្វះសារធាតុចិញ្ចឹម

**ប្រអប់គន្លឹះ៖**

រោគសញ្ញាអាចកើតមាននៅពេលរាំងស្ងួត របួសដោយថ្នាំគីមីកសិកម្ម ឬជម្ងឺ។ ប្រសិនបើមិនប្រាកដទេ សូមពិភាក្សាជាមួយអ្នកជំនាញ។

## ស្លឹក និងផ្លែនៅផ្នែកខាងលើ/ខ្ចី



**កង្វះស្ពាន់ធ័រ៖** ចាប់ផ្តើមលឿងដូចកង្វះអាសូត ប៉ុន្តែផ្តើមពីស្លឹកខ្ចី



**កង្វះកាល់ស្យូម៖** រលួយនៅផ្នែកខាងក្រោមផ្លែ រលាកនៅគែមស្លឹក ស្លឹកថ្មីចេញមកខូចទ្រង់ទ្រាយ

## ស្លឹកនៅផ្នែកខាងក្រោម/ចាស់



**កង្វះប៉ូតាស្យូម៖** ចាប់ផ្តើមឡើងលឿងនៅគែមៗស្លឹក



**កង្វះអាសូត៖** ចាប់ផ្តើមលឿងលើស្លឹក



**កង្វះម៉ាញ៉េស្យូម៖** ចាប់ផ្តើមលឿងនៅចន្លោះទ្រនុងស្លឹក



**កង្វះផូស្វ័រ៖** ចាប់ផ្តើមព៌ណស្វាយលើស្លឹក

# • ការគ្រប់គ្រងកង្វះសារធាតុចិញ្ចឹម




ធ្វើការពិនិត្យសារធាតុចិញ្ចឹមក្នុងដីជាទៀងទាត់ ដោយពិនិត្យរកមើលសារធាតុអាសូត (N) មុនរដូវកាលដាំដំណាំនីមួយៗ និងធ្វើការពិនិត្យរកមើលសារធាតុផូស្វ័រ (P) ប៉ូតាស្យូម (K) កាល់ស្យូម (Ca) ស្ពាន់ធ័រ (S) ម៉ាញេស្យូម (Mg) និង ប៉េហាស់ (pH) រៀងរាល់៥ឆ្នាំម្តង។



ដាក់ដី បន្ថែមកំបោរប្រសិនបើដីមានប៉េហាស់ (pH)ទាប ឬដីអាស៊ីត។ ពិគ្រោះយោបល់ជាមួយអ្នកជំនាញ។

## គំរូនៃជីអសរីរាង្គ និង ជីសរីរាង្គដែលអាចរកបាន

| ជីអសរីរាង្គ | | N | $P_2O_5$ | $K_2O$ |
|---|---|---|---|---|
| ជីសមាស | NPK ១៥-១៥-១៥ | ១៥ | ១៥ | ១៥ |
| | NPK ២០-២០-១៥ | ២០ | ២០ | ១៥ |
| | NPK ១០-២៦-២៦ | ១០ | ២៦ | ២៦ |
| ជីទ្វេធាតុ | ឌីអាម៉ូញ៉ូម ផូស្វាត (DAP) | ១៨ | ៤៦ | ០ |
| | អាម៉ូញ៉ូមផូស្វាត | ១៦ | ២០ | ០ |
| | ម៉ូណូប៉ូតាស្យូម ផូស្វាត | ០ | ៥២ | ៣៤ |
| ជីទោល | អ៊ុយរ៉េ | ៤៦ | ០ | ០ |
| | ប៉ូតាស្យូមក្លរ | ០ | ០ | ៦០ |
| | ផូស្វាត | ០ | ៣៦ | ០ |

*DAP ១០០គក គឺមិនស្មើនឹងអ៊ុយរ៉េ ១០០គកទេ
*DAP ១០០គក មាន N(អាសូត) ១៨ គក និង P2O5 (ផូស្វ័រ) ៤៦គក
*អ៊ុយរ៉េ ១០០គក មាន N (អាសូត) ៤៦គក

| ជីសរីរាង្គ | |
|---|---|
| ជីលាមកសត្វ | ជីលាមកគោ<br>ជីលាមកបក្សី<br>ជីលាមកមាន់ |
| កាកសំណល់រុក្ខជាតិ | ចំបើង<br>សណ្តែក<br>ដើមពោត |
| ផ្សេងៗ | ជីអាចម៍ជន្លេន<br>ជីបូកាឈិ<br>កាល់ផូស (សំបកពងមាន់/ ឆ្អឹង)<br>ការផ្អាប់ជីត្រី (FAA)<br>ការផ្អាប់ជីពីផ្លែឈើ (FFJ)<br>ការផ្អាប់ជីពីរុក្ខជាតិ (FPJ)<br>ការចំរាញ់សារ៉ាយសមុទ្រ |







ដំណាំដែលត្រូវការសារធាតុចិញ្ចឹមច្រើន
(ពោត ដំណាំអំបូរត្រសក់ ដំណាំអំបូរគ្រប់)

↓

ដំណាំដែលផ្តល់ផ្គង់សារធាតុចិញ្ចឹមច្រើន
(ដំណាំអំបូរសណ្តែក)

↓

ដំណាំដែលត្រូវការសារធាតុចិញ្ចឹមតិច
(ដំណាំអំបូរស្ពៃ)

*http://guides.eastwestseed.com*


មគ្គុទេសក៍បច្ចេកទេសនេះ គឺជាផ្នែកមួយនៃដំណើរការផលិតដោយ *EWSF* *©2017* រក្សាសិទ្ធិថតចំលងដោយ *East-West Seed Foundation* គ្រប់កម្មសិទ្ធិទាំងអស់ត្រូវបានរក្សាទុក។



*Agrochemical recommendations have been developed in cooperation with Wageningen University & Research*


WAGENINGEN UNIVERSITY & RESEARCH